# ការបាត់ខ្លួនដោយបង្ខំ (enforced disappearance)

វាសំដៅលើការឃាត់ខ្លួន (arrest) ការឃុំខ្លួន (detention) ឬការចាប់ជម្រិត (abduction) បុគ្គល ដោយមានការអនុញ្ញាត គាំទ្រ ឬ ទទួលយក (acquiescence) ដោយរដ្ឋ ឬ អង្គការចាត់តាំងនយោបាយ ដោយមិនទទួលស្គាល់ថាមានការដកហូតសិទ្ធិសេរីភាព (deprivation of freedom) ឬបដិសេធផ្តល់ព័ត៌មាន ស្តីពីជោគវាសនា ឬទីកន្លែងនៃបុគ្គលក្នុងបំណង ដកការការពារពីពួកគេ ក្នុងរយៈពេលយូរមួយ។[1]

នេះជាលើកដំបូង នៃការចាត់ការបាត់ខ្លួនដោយបង្ខំ ជាបទល្មើស។ Nuremburg charter មិនបានដាក់បញ្ចូលទេ។

តាមនិយមន័យនេះ មានពីរកម្រិត៖ ទី១. គឺការបដិសេធថាមិនដឹងពីការដកហូតសិទ្ធិសេរីភាព និងទី២ មានការទទួលស្គាល់ ក៏ប៉ុន្តែ មិនបានផ្តល់ដំណឹងអំពីទីកន្លែងឃុំខ្លួនជាដើម។ ដូចនេះ ជាដំបូង វាអាចមានការឃុំខ្លួនស្របច្បាប់ តែក្រោយមក បុគ្គលបានបាត់ខ្លួន។ ការឃុំខ្លួនស្របច្បាប់នេះ មិនអាចជាអំណះអំណាងសម្រាប់ជាការដោះសារឲ្យរួចខ្លួនទេ។

ក្នុងឆ្នាំ ២០០៦ មានអនុសញ្ញាស្តីពីការការពារបុគ្គលពីការបាត់ខ្លួនដោយបង្ខំ (Convention for the Protection against Enforced disappearance) ដែលនិយមន័យមានភាពខុសគ្នាពីការកំណត់ក្នុងលក្ខន្តិកៈ ICC ដោយដកចេញនូវពាក្យ “ចេតនាដកការការពារតាមច្បាប់”។

បទល្មើសនេះ ជាបទល្មើសបន្ត (continuous crime) ដែលវាបញ្ចប់នៅពេលដែល ជោគវាសនារបស់បុគ្គលបាត់ខ្លួន ត្រូវបានដឹង ហើយអាជ្ញាយុកាលនៃការចោទប្រកាន់ (statute of limitation) នឹងត្រូវចាប់ផ្តើមរាប់នៅពេលនោះ (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 309-310)។

---

[1] Article 7(1)(i) of Statute of ICC: enforced disappearance of person means the arrest, detention or abduction of persons by, or with the authorization, support or acquiescence of, a State or a political organization, followed by a refusal to acknowledge that deprivation of freedom or to give information on the fate or whereabouts of those persons, with the intention of removing them from the protection of the law for a prolonged period of time.